# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីបុណ្យមាឃបូជា

web site: hoksavann.org

ថ្ងៃទី២១ កុម្ភៈ ២០០៥

ពាក្យថា <មាឃបូជា> កាត់ជាពីរបទគឺ <មាឃ:>១បទ និង<បូជា> ១បទ ។ <មាឃ:>គឺជាឈ្មោះខែមួយក្នុងចន្ទគតិ គឺខែមាឃ ឯពាក្យថាបូជា ប្រែថាការថ្វាយ ការប្រគេន ការជូន ការប្រតិបត្តិតាម ។ រួមពាក្យទាំងពីរបទ ប្រែថាការបូជាក្នុងខែមាឃ ។ ពុទ្ធសាសនិកជនអ្នកកាន់ពុទ្ធសាសនាក្នុងលោក ជាពិសេសពុទ្ធសាសនិកជនខ្មែរ ធ្វើបុណ្យមាឃបូជាក្នុងខែមាឃនេះ ដោយប្រារព្ធបុព្វហេតុពីរប្រការគឺ ព្រះពុទ្ធសំដែងឱវាទបាតិ-មោក្ខ១ និងព្រះអង្គដាក់ជន្មាយុសង្ខារ១ ។ ការប្រជុំសម្តែងឱវាទបាតិមោក្ខនេះ ហៅថាចតុរង្គសន្និបាត ប្រែថាការប្រជុំប្រកបដោយអង្គ៤គឺ ១-ថ្ងៃនោះជាថ្ងៃ១៥កើតខែមាឃ, ២-ព្រះអរហន្តចំនួន១,២៥០អង្គមកជួបជុំគ្នានៅវត្តវេឡុវ័នក្រុងរាជគ្រឹះ ដោយឥតបានណាត់គ្នាជាមុនឡើយ, ៣-ព្រះអរហន្តទាំងនោះសុទ្ធតែបានសំរេចបដិសម្ភិទាញាណ (កន្លែងខ្លះថាបានសំរេចអភិញ្ញា៦), ៤- ជាឯហិភិក្ខុបានបួសក្នុងសំណាក់ព្រះពុទ្ធ ។ នេះជាបុព្វហេតុទី១ ។ បដិសម្ភិទាញាណមាន៤គឺ ១- ធម្មប្បដិសម្ភិទា-ញាណ ប្រាជ្ញាយល់ធម៌, ២- អត្ថប្បដិសម្ភិទា យល់សេចក្តីរបស់ធម៌, ៣-បដិភាណបដិសម្ភិទា ឈ្លាសវៃក្នុងការសម្តែងធម៌, ៤- និរុត្តបដិសម្ភិទា ឈ្លាវវៃក្នុងការប្រើភាសាឬប្រើពាក្យ ។ អភិញ្ញា៦គឺ ៖ ១- ឥទ្ធិវិធិ សំដែងឫទ្ធិផ្សេងៗបាន, ២- ទិព្វសោត ស្តាប់សម្លេងដែលមិនឮដល់ត្រចៀកបាន, ៣- ចេតោបរិញ្ញាណ ដឹងចិត្តអ្នកដទៃ, ៤- បុព្វេនិវាសានុស្សតិ រលឹកក្នុងកាលមុនៗបាន, ៥- ចតូបបាតញាណ ដឹងហេតុនៃចុតិបដិសន្ធិ, ៦-អាសវក្ខយញាណ ដឹងអរិយសច្ច៤ ជាទីអស់ទៅនៃអាសវ: ។ បុព្វហេតុទី៤ដែលនាំឲ្យធ្វើបុណ្យមាឃបូជា គឺព្រះអង្គដាក់ជន្មាយុសង្ខារថា នៅតែបីខែទៀតទេ ព្រះអង្គបរិនិព្វានហើយ ។ បុព្វហេតុទាំងពីរនេះកើតឡើងនៅថ្ងៃទី១៥កើតខែមាឃដូចគ្នា ដែលពុទ្ធបរិស័ទបានប្រារព្ធធ្វើនេះឯង ។

ពុទ្ធបរិស័ទប្រារព្ធធ្វើពិធីបុណ្យមាឃបូជានេះ ដើម្បីរំលឹកដល់ព្រឹត្តិ-ការណ៍ដែលកើតលើងនៅក្នុងសម័យពុទ្ធកាល ជាការគោរពគុណព្រះពុទ្ធដែលកើតមានចំពោះសព្វសត្វ ។ ចំពោះអានិសង្សដែលកើតអំពីការធ្វើបុណ្យមាឃបូជានេះ បើយោលទៅតាមព្រះពុទ្ធដីកា ដែលសំដែងអំពីការបូជាពីរប្រការគឺ សក្ការ:បូជា ការបូជាដោយគ្រឿងសក្ការ:បូជាទាំងឡាយ មានទៀនផ្កាជាដើមដល់ព្រះរតនត្រ័យ មានព្រះពុទ្ធជាដើម ចាត់ថាបានបុណ្យកុសលមួយផ្នែកហើយ ប៉ុន្តែព្រះពុទ្ធសំដែងថា ការបូជាឬការគោរពចំពោះព្រះពុទ្ធដ៏សំខាន់បំផុត គឺការប្រតិបត្តិតាមធម៌របស់ព្រះអង្គ ។ ព្រះពុទ្ធដីកាថា អ្នកឯណាមួយជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដ៏ត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ជាប្រក្រតី អ្នកនោះឈ្មោះថា ធ្វើសក្ការ: ធ្វើសេចក្តីរាប់អាន បូជាបូជានូវព្រះតថាគត ដោយបដិបត្តិបូជា ជាបូជាដ៏ឧត្តម ។ ព្រះពុទ្ធដីកាមួយកន្លែងមុនបរិនិព្វានថា ម្នាលអានន្ទ ធម៌និងវិន័យដែលតថាគតបានសំដែងហើយ បានបញ្ញត្តិហើយ បើអស់ពីតថាគតទៅ ធម៌និងវិន័យនោះ ជាគ្រូរបស់អ្នករាល់គ្នា ។ ម្នាលភិក្ខុទាំងឡាយ ពេលនេះតថាគតផ្តាំអ្នករាល់គ្នាជាចុងក្រោយ ចូរអ្នករាល់គ្នាធ្វើប្រយោជន៍ខ្លួន និងអ្នកដទៃឲ្យសម្រេចដោយសេចក្តីមិនប្រមាទចុះ ត្បិតសង្ខារទាំងឡាយមានការអស់ទៅ និងសូន្យទៅជាធម្មតា ។

បាតិមោក្ខមានពីរយ៉ាង គឺ១- អាណាបាតិមោក្ខ បានដល់ព្រះវិន័យរបព្រះភិក្ខុសង្ឃ គឺបាតិមោក្ខសំវរសីល ដែលមានសិក្ខាបទ២២៧ ដែលព្រះសង្ឃស្វូត្ររាល់កន្លះខែ ។ បាតិមាក្ខមួយទៀតហៅថាឱវាទបាតិមោក្ខ ដែលព្រះអង្គសំដែងក្នុងថ្ងៃ១៥កើតខែមាឃនេះឯង ឱវាទសំដែងពេលនេះមានច្រើនប្រការ ពេលនេះសូមលើកយកតែឱវាទ៣ប្រការមកបញ្ជាក់ខ្លះ ដែលព្រះអង្គសំដែងពេលនេះ ។ ឱវាទ៣ប្រការនោះគឺ ៖ ១- សព្វបាបស្ស អករណំ ប្រែថាការមិនធ្វើអំពើបាបគ្រប់យ៉ាង គឺជាខហាមមិនឲ្យប្រព្រឹត្តអាក្រក់ មានការបៀតបៀនអ្នកដទៃ ទាក់ទងការរំលោភសិទ្ធិមនុស្សជាដើម ។ ២- កុសលស្សូបសម្បទា ប្រែថា ការបំពេញកុសល គឺជាខឲ្យធ្វើសេចក្តីល្អ ដោយកាយវាចាចិត្ត ទាក់ទងនឹងចិត្តមានមេត្តាករុណាស្រឡាញ់រាប់អានជួយសង្គ្រោះអ្នកដទៃជាដើម ។ ៣- សចិត្តបរិយោទបនំ ប្រែថាជំនះចិត្តឲ្យស្អាតបរិសុទ្ធ ។ ការសំអាតចិត្តឲ្យបរិសុទ្ធនេះ ជាមូលដ្ឋានសំខាន់បំផុត ព្រោះសកម្មភាពល្អ កើតមកពីចិត្តបរិសុទ្ធ, បើចិត្តបរិសុទ្ធនឹងធ្វើតែអំពើល្អ និងធ្វើឲ្យបុគ្គលម្នាក់ៗ គ្រួសារមួយៗ និងសង្គមជាតិទាំងមូលបានសុខសន្តិភាព ។ បើពុទ្ធសាសនិកជនខ្មែរ ទាំងអ្នកដឹកនាំទាំងប្រជាពលរដ្ឋធ្វើតាមឱវាទរបស់ព្រះពុទ្ធ៣យ៉ាងនេះហើយ ឈ្មោះថាគោរពបុណ្យមាឃបូជាក្នុងថ្ងៃមាឃបូជានេះហើយ ។៚